## ខ្លឹមសារសង្ខេបអត្ថបទ

**Legal Malpractice ( Tort Liability of Attorney)**

**John L. Diamond and et al., Understanding Torts, 5th ed., 2013, pp. 103-104**

១. វិធាននៃការទទួលខុសត្រូវលើអំពើអនីត្យានុកូលពាក់ព័ន្ធការព្យាបាលខុសបច្ចេកទេស (medical malpractice) មិនខុសពីការទទួលខុសត្រូវលើអំពើអនីត្យានុកូល ពាក់ព័ន្ធការការពារក្តីខុសបច្ចេកទេស (attorney malpractice) ទេ។

២. ដើម្បីនាំឲ្យមានការទទួលខុសត្រូវ វាមានតម្រូវឲ្យមាននូវទំនាក់ទំនងរវាងកូនក្តីនិងមេធាវី ដែលបង្កើតនូវកាតព្វកិច្ចរបស់មេធាវី ក្នុងការពារក្តីអនុលោមតាមស្តង់ដារថៃទាំ (standard of care)។ ករណីមេធាវី បានបំពានកាតព្វកិច្ចនេះ មេធាវីនឹងទទួលខុសត្រូវលើអំពើអនីត្យានុកូល។ ការចាញ់លើផ្នែកមួយនៃបណ្តឹង មិនមែនជាកំហុស ដែលនាំឲ្យមានការទទួលខុសត្រូវទេ ព្រោះទាំងនោះ វាជាបច្ចេកទេសដោយឡែកៗរបស់មេធាវីក្នុងការការពារក្តី។ ស្រដៀងគ្នានេះដែរ គេក៏មិនអាចប្តឹងមេធាវី ផ្អែកលើសាលក្រមខុសឆ្គង ដែលអាចបណ្តាលមកពីសេចក្តីសន្និដ្ឋានការពាររបស់មេធាវីទេ។ អ្វីដែលមេធាវីអាចនឹងទទួលខុសត្រូវ គឺសកម្មភាព របស់គាត់ក្រោម ស្តង់ដារអប្បបរិមា ដែលគេទាមទារ ដូចជា ចំណេះដឹង និង ជំនាញ ដែលក្នុងនាមជាមេធាវី ត្រូវតែមាន។ ដូចនេះ ការធ្វេសប្រហែស មិនបានជួយប្តឹង ក្នុងពេលដែលខ្លួនមានសិទ្ធិ ធ្វើឲ្យខកខានក្នុងការប្តឹង អាចនឹងនាំឲ្យមានការទទួលខុសត្រូវ។ ទោះបីជាយ៉ាងនេះក្តី អ្នកប្តឹងមេធាវី ត្រូវតែបង្ហាញថា ប្រសិនបើបានប្តឹងទាន់ពេល នោះខ្លួនមិនបាត់បង់នូវប្រយោជន៍ទេ។ នេះបង្ហាញនូវចំណងហេតុ ឬផល (causation) និងទ្រឹស្តី “but for test”។

**ខ្លឹមសារដកស្រង់៖** *ប្រសិនបើមេធាវី ផ្តល់យោបល់ដល់កូនក្តីមិនសមស្រប ដោយសារកំហុសមិនយល់ដឹងច្បាប់ គាត់បានបំពានកាតព្វកិច្ច ធៀបនឹង មេធាវីផ្សេង ដែលបានពិចារណាច្បាប់ត្រឹមត្រូវ*។

**ពាក្យគន្លឹះ៖** but for test, ចំណងហេតុ និងផល, medical malpractice